

# មិនមាននរណាម្នាក់ត្រូវបានទុកចោលឡើយ

ដោយអែលឌើរ ហ្គេរ៉ី ប៊ី សាប៊ីន
ក្នុងពួកចិតសិបនាក់

« *ចូរឲ្យគ្រប់គ្នាមានគំនិតតែ១ ព្រមទាំងមានចិត្តអាណិតអាសូរ ហើយស្រឡាញ់គ្នាជាបងប្អូន* » ( *ពេត្រុស ទី១ ៣:៨* ) ។

ចាស្ទីន កូនប្រុសរបស់យើងបានធំឡើងជាមួយនឹងជំងឺដ៏ពិបាកមួយ ។ ជួនកាលគាត់ខ្សោយណាស់ ។ គាត់មិនតែងតែអាចធ្វើអ្វីៗដូចមនុស្សគ្រប់គ្នាធ្វើឡើយ ទោះជាគាត់បានព្យាយាមក្តី ។ គាត់បានដឹងថាវាមានអារម្មណ៍យ៉ាងណាដែលខុសពីគេនោះ ។

ថ្ងៃមួយ ចាស្ទីន និងមិត្តភក្តិរបស់គាត់បានជួបជុំគ្នាដើម្បីលេងល្បែងមួយ ។ ពួកគេត្រូវវាយបាល់ជាមួយនឹងដៃពួកគេ ដើម្បីកុំឲ្យបាល់នោះធ្លាក់ចុះ ។ មានក្មេងស្រីបាក់ដៃម្នាក់បានមកលេងជាមួយ ។

វាងាយស្រួលដើម្បីនិយាយថា « មែនហើយ យើងទាំងអស់គ្នានឹងលេង ហើយនាងនឹងមើល » ។

ផ្ទុយទៅវិញ ចាស្ទីនបាននិយាយថា « ខ្ញុំមានគំនិតល្អមួយ ។ យើងទាំងអស់គ្នានឹងលេងជាមួយគ្នាដោយប្រើដៃតែម្ខាងប៉ុណ្ណោះ » ។ គ្រប់គ្នាបានលេងដោយប្រើដៃតែម្ខាង រួមទាំងក្មេងស្រីដែលមានពាក់រណបនៅនឹងដៃនោះផងដែរ ។ មិនមាននរណាម្នាក់ត្រូវទុកចោលឡើយ ។

ចាស្ទីនគឺជាវីរបុរសរបស់ខ្ញុំ ។ គាត់តែងតែមើលទៅមនុស្សផ្សេងទៀត ហើយគិតថា *តើពួកគេមានអារម្មណ៍យ៉ាងណា* ? ចាស្ទីនឈឺភាគច្រើនបំផុតនៃជីវិតរបស់គាត់ ប៉ុន្តែគាត់រីករាយដោយសារគាត់បានជួយមនុស្សដទៃទៀត ហើយធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។

យើងទាំងអស់គ្នាមានឧបសគ្គ ប៉ុន្តែយើងមានអ្វីៗជាច្រើនដែលធ្វើឲ្យយើងសប្បាយ ។ ធ្វើអ្វីដែលអ្នកអាចធ្វើបាន ។ សូមទុកចិត្តលើព្រះ ។ សុភមង្គលដ៏អស្ចារ្យបំផុតមិនមែនបានមកពីការផ្តោតលើខ្លួនឯងទេ ប៉ុន្តែបានមកពីការផ្តោតលើអ្នកដទៃទៀត ។ ●



រចនារូបភាពដោយ បាបារ៉ា បុនហ្គីនី